ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៥១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលព្រំប្រទល់រដ្ឋបាលខណ្ឌ នៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលខណ្ឌ នៃរាជធានីភ្នំពេញ ដូចខាងក្រោមៈ

- កែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខណ្ឌមានជ័យ ជាមួយខណ្ឌទួលគោក និងខណ្ឌចំការមន ដោយយកអ័ក្សផ្លូវលេខ២៧១ ធ្វើជាព្រំប្រទល់រដ្ឋបាលថ្មី ដោយគិតចាប់ពីព្រំប្រទល់ខណ្ឌសែនសុខ រហូតដល់មហាវិថីព្រះនរោត្តម
- កែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខណ្ឌមានជ័យ និងខណ្ឌដង្កោ ដោយយកអ័ក្សផ្លូវលេខ៣៧១ និងផ្លូវលំមានស្រាប់ ធ្វើជាព្រំប្រទល់រដ្ឋបាលថ្មី
- កែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខណ្ឌឫស្សីកែវ ជាមួយខណ្ឌទួលគោក និងខណ្ឌដូនពេញ ដោយយកអ័ក្សផ្លូវលេខ៥៩៨ ផ្លូវលេខ៣៥៥ ផ្លូវលេខ២៧៨ និងផ្លូវលេខ៧០ ធ្វើជាព្រំប្រទល់រដ្ឋបាលថ្មី
- កែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខណ្ឌពោធិ៍សែនជ័យ ជាមួយខណ្ឌដង្កោ ខណ្ឌមានជ័យ និងខណ្ឌសែនសុខ ដោយយកផ្លូវធ្វើជាព្រំប្រទល់រដ្ឋបាលថ្មី
- កែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខណ្ឌដូនពេញ ជាមួយខណ្ឌចំការមន និងខណ្ឌជ្រោយចង្វារ ត្រង់ទន្លេចតុមុខ
- កែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខណ្ឌព្រែកព្នៅ និងខណ្ឌឫស្សីកែវ ដោយយកអ័ក្សផ្លូវទំនប់កប់ស្រូវ ធ្វើជាព្រំប្រទល់រដ្ឋបាលថ្មី ដោយគិតចាប់ពីស្ថានីយ៍បូមទឹកកប់ស្រូវ ដល់ផ្លូវជាតិលេខ៥។

ផ្អែកតាមការកែសម្រួលនេះ ព្រំប្រទល់រដ្ឋបាលខណ្ឌ នៃរាជធានីភ្នំពេញ ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានីភ្នំពេញ គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌសែនសុខ គណៈអភិបាលខណ្ឌសែនសុខ ក្រុមប្រឹក្សាសង្កាត់ភ្នំពេញថ្មី និងក្រុមប្រឹក្សាសង្កាត់គោកឃ្លាង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

